# ចំលើយកសិណរបស់លោក វ៉ាអ៊ូល ចេណា នៅក្នុងសវនាការរបស់ ឌុច

## លោកប្រធានអស់លោក លោកស្រីជាសមាជិក សមាជិកានៃសាលាជំនុំជំរះក្តី

១. គឺដោយមនោសញ្ចេតនារំភើបយ៉ាងក្រៃលែងដែលខ្ញុំបានមកធ្វើអន្តរាគមន៍នៅចំពោះមុខអង្គ តុលាការនេះ ។ រំភើបគឺដោយរូបខ្ញុំបានដឹងយ៉ាងច្បាស់ពីចរិតជាប្រវត្តិសាស្ត្រនៃសវនាការនេះ ។ រំភើបពីព្រោះយើងមិនគ្រាន់តែរំលឹកនូវព្រឹត្តការណ៍នានាជាប្រវត្តិសាស្ត្រប៉ុន្នោះទេ ប៉ុន្តែនេះគឺទាក់ទិនទៅនឹងរឿងរស់និងពិសេសរឿងស្លាប់ រឿងការឈឺចាប់ដ៏ធំធេង និង ជារួមទាក់ទិនទៅនឹងការ លេចចេញជាថ្មីម្តងទៀតនូវអំពើឃោរឃៅ ក្នុងពេលដែលមនុស្សស្រករខ្ញុំបានលង់លក់ទៅក្នុងឃ្លា ««**មិនត្រូវអោយអំពើឃោរឃៅនេះកើតឡើងវិញជាដាច់ខាត**»» ដែលបានថ្លែងដោយ sir Hartley Shawcross អគ្គរាជអាជ្ញាអង់គ្លេសនៅក្នុងដីកាសន្និដ្ឋានចុងក្រោយរបស់លោកនៅចំពោះមុខតុលាការ Nuremberg ។ អាស្រ័យដោយហេតុនេះហើយ ជាបឋមអនុញ្ញាតអោយរូបខ្ញុំលំអោនកាយគោរពវិញ្ញាណក្ខន្ធនៃអ្នករងគ្រោះដោយរបប **កម្ពុជាប្រជាធិបតេយ្យ** និង សូមសំដែងនូវសមានចិត្ត និង ករុណា ធម៏ចំពោះអ្នកដែលបានរស់រានមានជីវិត ។

២. លទ្ធិផ្តាច់ការស្តាំនិយមត្រូវបានកាត់ទោសនៅ Nuremberg និងនៅ Tokyo ។ លទ្ធិផ្តាច់ការដែលឈរលើតំលៃឆ្វេងនិយមមិនដែលត្រូវបានកាត់ទោសម្តងណាឡើយមកដល់ពេលនេះ ។ ហេតុនេះហើយតុលាការនេះគឺប្រហែលជាតុលាការតែមួយគត់ដែលកាត់ទោសឧក្រិដ្ឋកម្មនៃលទ្ធិផ្តាច់ការមួយដែលត្រូវបានយកមកអនុវត្តក្នុងនាមនៃការរើបំរះដណ្តើមយកសេរីភាពរបស់ប្រជាជននានា ។

៣. ខ្ញុំមិនមែនជាអ្នកផ្តាញ់ផ្តាល់មនោគមន៍វិជ្ជាហើយអោយតំលៃថាមនោគមន៍វិជ្ជាណាល្អជាងណាទេ។ រឹសគល់នៃលទ្ធិកុំមុយនីសនិយមខុសឆ្ងាយណាស់ពីរឹសគល់នៃលទ្ធិផាស៊ីសនិយម ឬ លទ្ធិយោធា និយម ។ ប៉ុន្តែនៅពេលណាដែលពួកអ្នកគាំទ្រមនោគមន៍វិជ្ជាមួយបានជ្រើសរើសយកការបង្ខិតបង្ខំជាជាងការបញ្ចុះបញ្ចូល ពួកគេបានធ្លាក់ចូលក្នុងជំរើសនូវវិធីដូចគ្នា និង ក្នុងសម្បទាតែមួយដូចគ្នាក្នុងការបំផ្លាញឆន្ទៈរបស់បុគ្គល និង ភាពថ្លៃថ្នូរដែលមានជាប់នៅនឹងមនុស្សគ្រប់រូបហើយ ។

៤. នៅទីនេះ និង ក្នុងពេលនេះ គឺជាការវិនិច្ឆ័យទោសទៅលើអ្វីដែលចំពោះខ្ញុំៗហៅថា**លទ្ធិប៉ុលពត និយម** និង ដើម្បីធ្វើការត្រួតពិនិត្យទៅលើអ្វីដែលថាការដាក់អោយដំណើរការនូវការច្នៃបែបខ្មែរនូវ មនោគមន៍វិជ្ជាកុំមុយនីសនេះបាននាំ

ទៅដល់ភាពឃោរឃៅមួយដែលសមនឹងការអោយឈ្មោះថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ជាការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងសឺនែវនោះ ។

៥. ហេតុនេះហើយត្រូវតែដំណើរការវិនិច្ឆ័យទោសនេះ ។ តែការវិនិច្ឆ័យទោសមិនគឺជាបឋមជាការងារ ស្វែងយល់និងពន្យល់ទេឬ ? មិនគឺគុណធម៌បឋមនៃយុត្តិធម៌ជាការពន្យល់នូវការប្រព្រឹត្តដើម្បីអាចដាក់បង្ហាញដល់សង្គមនូវមូលហេតុ និង មធ្យោបាយនានាដើម្បីចៀសវាងកុំអោយទំវើទាំងនោះកើតឡើង បានជាថ្មីទៀតទេឬ ? គ្មានកន្លែងណាក្រៅពីកម្ពុជាទេក្នុងបច្ចុប្បន្នកាលនេះ ដែលគេអាចលើកយកមកអនុវត្តបានយ៉ាងសមស្របបំផុតនូវពាក្យដ៏រន្ធត់របស់លោក Primo Levi ដែលជាអ្នកបានរស់រានពីជំរំ ប្រល័យពូជសាសន៍ Auschwitz ដែលលោកបាននិយាយថា: ««*អ្នកណាដែលធ្វើមិនដឹងមិនលឺពីអតីតកាលរបស់ខ្លួនរមែងរងទទួលនូវការកើតឡើងវិញនូវអតីតកាល នេះជានិច្ច*»» ។

៦. ពន្យល់ដើម្បីយល់ ។ ហើយដូចជាសេចក្តីថ្លែងរបស់លោក Fran–ois Bizot បានថ្លែងនៅក្នុងទីនេះ យ៉ាងត្រឹមត្រូវថា:««*ស្វែងយល់មិនមែនមានន័យថាលើកលែងទោសនោះទេ*»» ។ ហើយនេះក៏ជាសេចក្តី ថ្លែងរបស់ខ្ញុំដែរ ។

៧. លោកប្រធាន ។ រូបខ្ញុំត្រូវបានស្នើដោយចុងចោទអោយធ្វើជាកសិនសាក្សីជំនាញការប៉ុន្តែខ្ញុំសូម បញ្ជាក់ថាខ្ញុំមកទីនេះមិនមែនមកការពាររបបមួយដែលគ្មានផ្តល់អោយខ្ញុំអ្វីក្រៅតែពីការស្អប់ខ្ពើមតែ ប៉ុននោះឡើយ ។ ខ្ញុំមកទីនេះហើយដែលនៅពេលនេះខ្ញុំនឹងខិតខំប្រឹងប្រែងនោះ គឺសាកល្បងពន្យល់នូវរបបផ្តាច់ការមួយដែលបាននាំទៅដល់ភាពឃោរឃៅ ។ ខ្ញុំមកទីនេះ ដើម្បីប្រឹងប្រែងធ្វើបទបង្ហាញនូវអ្វីដែលការសំរេចនៃអង្គជំនុំជំរះ របស់លោកហៅថា: ««*រាល់មូលដ្ឋានទ្រឹស្តីនិងជាក់ស្តែងទាំងឡាយ នៃរបបដ៏គួរអោយខ្លាចរន្ធត់ញាប់ញ័រដែលកម្ពុជាប្រជាធិបតេយ្យបានបង្កើតឡើង ព្រមទាំងទំរង់នៃការអនុវត្តទាំងឡាយដោយគួសបញ្ជាក់ថាតើនៅក្នុងកំរិតណាដែលពួកអាជ្ញាធរក្នុងសម័យនោះបានប្រើ សប្បដិភ័យនេះដើម្បីដឹកនាំប្រទេស ព្រមទាំងលើកឡើងនូវផលវិបាកនានាដែលរបបនេះបានបង្កឡើងទៅលើអាកប្បកិរិយារបស់មនុស្ស*»» ។

៨. ខ្ញុំបានយល់ព្រមទទួលសំនើរបស់ចុងចោទដើម្បីមកទីនេះនៅក្រោមលក្ខខណ្ឌពីរ: ខ្ញុំត្រូវតែមានសេរីភាពក្នុងការបញ្ចេញមតិទាំងស្រុង និង ខ្ញុំអាចជួបជាមួយចុងចោទ ។ ខ្ញុំយល់ថាមិនចាំបាច់គូសបញ្ជាក់ទេថាសំដីរបស់ខ្ញុំគឺគ្មានការខាឃាំងឡើយ ។ ផ្ទុយទៅវិញ ខ្ញុំយល់ថាជាការចាំបាច់ដែលត្រូវគូសបញ្ជាក់ពីកិច្ចសហការយ៉ាងពេញលេញរបស់ចុងចោទដែលបានឆ្លើយតបទៅ នឹង រាល់សំនួរដែលខ្ញុំបានសួរនៅរាល់ពេលដែលខ្ញុំបានជួបសន្ទនាជាមួយចុងចោទអស់រយ:ជិតប្រាំមួយខែនេះ ។

៩. ខ្ញុំមានបំនងចង់អោយការពន្យល់ទាំងឡាយរបស់ខ្ញុំ នឹងជួយអោយយល់បាននូវអ្វីដែលលោក **វ៉ាន់ណាត** ដែលជាជនរងគ្រោះម្នាក់របស់**ឌុច** បានទទួលស្គាល់យ៉ាងសប្បុរសថាតើហេតុអីបានជាពេជ្ឈឃាតម្នាក់បែរជាក្លាយជាជនរងគ្រោះមួយបែបនៃរបបដែលខ្លួនបានបំរើនោះទៅវិញផងដែរ ។

១០. របបមួយ ។ ពីព្រោះអស់លោកច្បាស់ជាឯកភាពផងដែរហើយថានេះជាការវិនិច្ឆ័យទោសទាំងរបប ទាំងអ្នកដែលទទួលអនុវត្តតាមរបបនេះ ។ គេមិនអាចធ្វើជាមិនដឹងបានទេថា នៅក្នុងប្រទេសកម្ពុជាមានការរួមគំនិតប្រទូសរ៉ាយឧក្រិដ្ឋមួយដែលចេញពីក្រុមបុរសនារីមួយក្រុមតូច ដើម្បីដាក់ប្រជាជនទាំងមូលអោយក្លាយជាទាសករនៃអង្គការចាត់តាំងមួយដែលបានសំរេចចិត្តដាក់បង្ខំនូវទំរង់ វិចល្លាស (ali"nation) ទាំងស្រុងមួយដែលមិនដែលមានសង្គមមនុស្សណាមួយធ្លាប់ឆ្លងកាត់ឡើយ។
ការរួមគំនិតប្រទូសរ៉ាយនេះបានចាប់កំនើតនៅក្នុងការចុះចូលក្រុមតូចនេះទៅក្នុងមនោគមន៍វិជ្ជាមួយដែលក្នុងនាមនៃការរើបរំដោះដណ្តើមយកសេរីភាពរបស់ប្រជាជននានាបានប្រែក្លាយទៅជាទំរង់ដ៏គ្មាន មេត្តាមួយនៃទាសភាព ។ គឺពួកមនុស្សនៃក្រុមតូចនេះហើយ ដែលជាពួកអនាគតអ្នកដឹកនាំនៃរបប **កម្ពុជាប្រជាធិបតេយ្យ**នោះ ។

## បុព្វគាមី (ant"c"dent) ផ្នែកមនោគមន៍វិជ្ជាទាំងឡាយ

១១. ពីព្រោះនេះជាចំនុចទីមួយដែលខ្ញុំចង់លើកឡើង ពោលគឺបុព្វគាមីផ្នែកមនោគមន៍វិជ្ជាទាំងឡាយដែលបានជះឥទ្ធិពលដល់ផ្នត់គំនិតរបស់ អង្គការ នាដើមដំបូងទី ។ ចំពោះ**បក្សកុំមុយនីសកម្ពុជា** នោះគឺ ព្រឹត្តការណ៍ឆ្នាំ ១៩១៧ និងអ្វីដែលកើតមានជាបន្តបន្ទាប់មកទៀត ។ នៅក្នុងអត្ថបទដ៏ល្បីល្បាញរបស់ ខ្លួននាឆ្នាំ ១៩៥២ ដែលមានចំនងជើងថាៈ««***រាជានិយម ឬ ប្រជាធិបតេយ្យ?***»» និង ដែលបានបោះផ្សាយក្នុងកាសែត **ខេមរៈនិស្សិត** ដែលជាព្រឹត្តិប័ត្រនៃសមាគមនិស្សិតខ្មែរនៅទីក្រុងប៉ារីសនោះ **ប៉ុលពត** ដែលបានដាក់ឈ្មោះលើអត្ថបទខ្លួនថា **ខ្មែរដើម** នោះមិនបានយោងបន្តិចណាសោះឡើយទៅលើ បដិវត្តន៍វៀតណាមឆ្នាំ ១៩៥៤ ក៏ដូចជាមិនយោងទៅបដិវត្តន៍ចិនឆ្នាំ ១៩៤៩ ផងដែរ ។ គាត់លើកឡើង ឆ្នាំ ១៩១៧ ។

១២. ខ្ញុំសូមឯកភាពជាមួយជំនឿដ៏មុតមាំរបស់លោក Steve Heder ផងដែរ ដែលថាប្រភពដើមចមនៃលទ្ធិកុំមុយនីសបែបប៉ុលពត គឺបដិវត្តន៍**បុលឆេវិច** ។ ដោយមិនបានបំភ្លេចចោលនូវតួនាទីរបស់ពួកកុំមុយនីសវៀតណាមនៅក្នុងការបណ្តុះបណ្តាលមនោគមន៍វិជ្ជា និង យោធាដល់ពួកកុំមុយនីសកម្ពុជា និង ដោយមិនបន្ថយអោយនៅតូចនូវសារសំខាន់នៃគំរូចិនក្នុងនយោបាយកសិកម្មរបស់**កម្ពុជាប្រជា ធិបតេយ្យ** (លើកលែងតែកំរិតនៃសមូហភាវ

កម្ម និង ការបំបែកគ្រួសារនៅជនបទដែលប្រទេសចិនមិន ដែលឈានដល់កំរិតនេះ) គេមិនអាចប្រកែកបានទេថា រាល់ចំនាត់តាំងនយោបាយ និងជាពិសេសចំនាត់តាំងបក្សកុំមុយនីសដោយរួមទាំងបញ្ញត្តិ និង ការអនុវត្តទាំងឡាយ នៅក្នុងបញ្ហាសន្តិសុខផង គឺ ដើរតាមគំរូ **បុលឆេវិច** ។

១៣. ក្រុមតូចនេះដែលក្រោយមកទៀតបានក្លាយជាអង្គការដឹកនាំរបស់របប**កម្ពុជាប្រជាធិបតេយ្យ** មានជាសំខាន់គឺ ពួកសមាជិកនៃ **មណ្ឌលលទ្ធិម៉ាក្សនៃនិស្សិតខ្មែរ** នៅក្នុងទីក្រុងប៉ារីស ពោលគឺជាក្រុមពិភាក្សាមួយដែលត្រូវបាន បង្កើតឡើងនៅឆ្នាំ ១៩៥១ ។ មនុស្សជាច្រើននៅក្នុងក្រុមនេះកាលពីសម័យ នោះ ជាសមាជិក**បក្សកុំមុយនីសបារាំង** ។ ហើយអ្នកណាក៏ដឹងដែរថាក្នុងចំនោមបក្សកុំមុយនីសដ៏សកម្មនានានៅក្នុងបស្ចិមប្រទេស**បក្សកុំមុយនីសបារាំង** គឺជា បក្សដែលមានភក្តីភាពឥតងាករេបំផុត ចំពោះរាល់នយោបាយទាំងឡាយដែលត្រូវបានសំរេចនៅទីក្រុង**ម៉ូស្គូ** ។ គណបក្សនេះស្ម័គ្រស្មោះបំផុតនឹងលោក**ស្តាលីន** ។ ហើយកាលពីសម័យនោះមួយភាគបួននៃអ្នកបោះឆ្នោតបារាំង បានផ្តល់សេចក្តីទុកចិត្តរបស់ខ្លួនទៅលើ**គណបក្សកុំមុយនីសបារាំង**នេះ ។

១៤. ពពួកសមាជិកនៃមណ្ឌលនេះ គឺជាអ្នកចូលរួមយ៉ាងទៀងទាត់ក្នុងវគ្គសិក្សានៃ សកលវិទ្យាល័យសម័យ របស់ **បក្សកុំមុយនីសបារាំង** ហើយក៏ជាអ្នកអានយ៉ាងទៀងទាត់នូវកូនសៀវភៅរបស់គណបក្សនេះ ព្រមទាំងកាសែត L"Humanit" ដែលក្នុងសម័យនោះជាអង្គការចាត់តាំងនៃគណៈមជ្ឈិម**បក្សកុំមុយនីស បារាំង** ។

១៥. នៅឯ ផ្ទះឥណ្ឌូចិន ដែលស្ថិតនៅក្នុងបុរីសកលវិទ្យាល័យ ដែលជានិវេសនដ្ឋានសំរាប់ពួកនិស្សិតនោះមានសាខា មួយរបស់**គណបក្សកុំមុយនីសបារាំង** ។ សាខានេះមាននិស្សិតខ្មែរចំនួនប្រាំបួននាក់ ។ នៅពេលដែល ផ្ទះកម្ពុជា ត្រូវបានបង្កើតឡើង សាខាមួយដែលមានទំរង់ដូចគ្នានេះត្រូវបានចាត់តាំងឡើង ។ ពួកខ្មែរដែលរស់នៅក្នុងទីក្រុងដូចជា **ប៉ុលពត**ជាដើមនោះ បានចូលរួមក្នុងសាខាបក្សកុំមុយនីសនៅ តាមសង្កាត់រៀងៗខ្លួន ។

១៦. វគ្គបណ្តុះបណ្តាលនានាដែលរៀបចំឡើងដោយ**គណបក្សកុំមុយនីសបារាំង**មានចែងពីប្រវត្តិនៃការបង្កើតគណ បក្សនេះដែលចេញពីឆន្ទៈរបស់ពួកសង្គមនិយមភាគច្រើនចង់ចូលរួម Internationale ទី៣ ពោលគឺជាចលនា កុំមុយនីសអន្តរជាតិ ។ ហើយការចូលរួមបែបនេះមានន័យជាការគោរពតាមលក្ខ ខណ្ឌទាំង ២១ ដែល**លេនីន**ខ្លួនឯង បានប្រកាសអោយអនុវត្តតាម ។ ក្នុងលក្ខខណ្ឌទាំង ២១ នេះ គេបានឃើញមានពីកាតព្វកិច្ចអនុវត្តនៅក្នុងផ្ទៃ គណបក្សនូវ«««**វិន័យដែក**»» ពីការដាក់សារព័ត៏មានទាំងអស់ និង រាល់មធ្យោបាយបោះពុម្ពទៅក្រោមអំនាចគណៈ មជ្ឈិមបក្ស ពីការកៀសចេញជាប្រព័ន្ធនូវរាល់សមាសភាពកំនែទំរង់និយមនិងកណ្តាលនិយម និង ពីការរៀបចំឡើង នូវអង្គការចាត់តាំងសំងាត់មួយ ដោយរួមបញ្ចូលពីការអនុវត្តការលាក់ការណ៍ដែលការរៀបចំនេះទាមទារ ។

១៧. លក្ខខណ្ឌទី ១២: (É.) *គណបក្សកុំម្មុយនីសអាចបំពេញតួនាទីរបស់ខ្លួនបានល្លឹកណាតែគណបក្សនេះត្រូវបានចាត់តាំងឡើងតាមរបៀបប្រមូលផ្ដុំបំផុត ល្លឹកណាតែបក្សមានវិន័យដែកស្មើរតែស្មើនឹងវិន័យយោធា និង ល្លឹកណាដែលអង្គការមជ្ឈឹមរបស់ខ្លួនមានអំនាចយ៉ាងទូលំទូលាយមានអំនាចដែលគ្មានអ្នកណាជំទាស់បាន និង ទទួលបានការទុកចិត្តជាឯកច្ឆ័ន្ទពីសកម្មជនរបស់ខ្លួន* ។

១៨. លក្ខខណ្ឌទី ១៣: *គណបក្សកុំម្មុយនីសនៅក្នុងបណ្ដាប្រទេសដែលអនុញ្ញាតអោយជនកុំម្មុយនីសធ្វើសកម្មភាពស្របច្បាប់បានត្រូវតែធ្វើការបោសសំអាតផ្ទៃក្នុងរបស់ខ្លួនអោយបានទៀងទាត់ដើម្បីច្រានចោលនូវរាល់សមាសភាពរកផលប្រយោជន៍ និង ពួកអនុធន* ។

១៩. ជាការសំខាន់មួយផងដែរដែលត្រូវកត់សំគាល់ថា ពួកនិស្សិតខ្មែរដែលបានចូលក្នុង**គណបក្សកុំម្មុយនីសបារាំង**សុទ្ធតែត្រូវបានបណ្ដុះបណ្ដាលទៅតាមស្មារតីមួយដែលថាគណបក្សកុំម្មុយនីសត្រូវតែអនុវត្តវិន័យដែក និង ត្រូវតែកំចាត់អ្នកប្រឆាំង និង អ្នកទន់ជ្រាយ ។

២០. បទសំភាសន៍នានាជាមួយបណ្ដាសមាជិក**មណ្ឌលលទ្ធិម៉ាក្សនៃនិស្សិតខ្មែរ** ដែលនៅរស់រានមានជីវិត គឺពោរពេញ ដោយព័ត៍មានសំរាប់ឆ្លើយទៅនឹងសំនួរទាំងឡាយដែលបានចោទមកលើយើង ។ ជាការពិតណាស់ព័ត៍មានទាំងនេះ បានអោយយើងដឹងថាក្នុងចំនោមសៀវភៅនានារបស់**ម៉ាក្ស លេនីន ស្តាលីន** និង **ម៉ៅ** វណ្ណកម្មពីរត្រូវបានក្លាយជា កម្មវត្ថុនៃអំនានដ៏ម៉ត់ចត់ និង ការពិភាក្សាដ៏សកម្មនៅក្នុងមណ្ឌលនេះ ។ វណ្ណកម្មទាំងពីរនោះគឺ៖

- **លេនីន:** រដ្ឋនិងបដិវត្តន៍ ( L‟Etat et la R‟volution ) ។

- **ស្តាលីន:** បណ្ដាគោលការណ៍នៃលទ្ធិលេនីន (Principe du L‟ninisme នៅក្នុងការបោះពុម្ពជាភាសារុស៊ីចំនងជើងដាក់ថា: សំនួរទាំងឡាយទាក់ទងទៅនឹងលទ្ធិលេនីន - Questions du L‟ninisme ) ។

២១. នៅក្នុងវណ្ណកម្មទីមួយ លោក**លេនីន**បានគូសបញ្ជាក់ពីលទ្ធភាពនៃការធ្វើបដិវត្តន៍ទោះបីជាគ្មានវត្តមាននៃវណ្ណៈអធនក្តី នោះគឺនៅពេលណាដែលប្រជារាស្ត្រជាភាគច្រើនទទួលឈឺចាប់ពីការជិះជាន់ និង ការគាបសង្កត់ហើយបានងើបបង្រះយ៉ាងខ្លាំងក្លាដើម្បីកំទេចសង្គមចាស់និងកសាងសង្គមថ្មីមួយឡើង ។ ក្នុងសៀវភៅនេះ គេឃើញនូវ

គោលគំនិតមួយ ហើយដែល**ម៉ៅសេទុង**បានយកមកប្រើផងដែរនោះគឺថានៅពេលដែលវណ្ណៈជិះជាន់ត្រូវផ្តួលរំលំហើយក្តី ក៏វណ្ណៈនេះនៅតែនៅខ្លាំងក្លាជាងវណ្ណៈដែលបានផ្តួលរំលំខ្លួនដែរ ហើយជ័យជំនះនៃកំលាំងមហាជនក៏មិន មានន័យថាកំលាំងអភិជនលែងក្លាយជា គ្រោះកំហែងហើយដែរទេ ។

២២. វណ្ណកម្មទីពីរមានលក្ខណៈជាពិសេសរបស់វា នេះបើតាមសំដីរបស់ជនចុងចោទផ្ទាល់ដែលថា ចាប់ពីឆ្នាំ ១៩៧០ មក រាល់សមាជិកថ្មីរបស់ **បក្សកុំមុយនីសកម្ពុជា** ត្រូវតែអានកូនសៀវភៅនេះ ។ បើ យោងទៅលើសំនេររបស់**ស្តាលីន** នៅក្នុងជំពូក៨ ដែលទាក់ទិនទៅនឹងការងារបក្សយើងឃើញនូវលក្ខខណ្ឌដ៏ល្បីល្បាញរបស់**លេនីន**សំរាប់ចូលជាសមាជិក Internationale **ទី ៣** ។ យើងដឹងហើយថា អាំងទែណាស្យូណាលទី៣ (ភាសារុស៊ីហៅថា កុំមីនទែន - Komintern) ត្រូវបានរំលាយចោលនាឆ្នាំ១៩៤៣ តែក៏ត្រូវបានប្តូរជំនួសវិញដោយ Kominform នាឆ្នាំ ១៩៤៧ ។ ហើយទំនាក់ទំនងរវាងសហភាពសូវៀត ជាមួយគណបក្សកុំមុយនីសនៃប្រទេសនានាក៏មិនបានប្រែប្រួលដែរទេ ។ កិច្ចពិណនាពីតួនាទីរបស់បក្សគួរតែត្រូវបានពិនិត្យបន្តិចដើម្បីអាចយល់បានពីអ្វីដែលគេបានបណ្តុះគំនិតរបស់អនាគតអ្នកដឹកនាំនៃ**កម្ពុជាប្រជាធិបតេយ្យ:**

- បក្សជាកងឈានមុខនៃវណ្ណៈអធនដែលបក្សមានភារកិច្ចចង្អុលបង្ហាញផ្លូវ និង ដឹកនាំ ។

- បក្សជាអង្គភាពចាត់តាំងឯកភាព ។ បក្សមានតួនាទីចាត់តាំងនិងគ្រប់គ្រងវណ្ណៈអធន ។ បក្សគឺជាឧបករណ៍នៃអំនាចផ្តាច់ការរបស់វណ្ណៈអធន ។

- បក្សត្រូវតែមានការចាត់តាំងក្នុងលក្ខណៈប្រមូលផ្តុំបំផុតហើយត្រូវគ្រប់គ្រងដោយ«« ***វិន័យដែកប្រហាក់ប្រហែលទៅនឹងវិន័យយោធា*** »» ។

២៣. **ស្តាលីន**បានយោងទៅលើ**លេនីន**នៅពេលដែលគាត់បញ្ជាក់ថា««ស្នូលរបស់បក្សគឺជាអង្គការមួយដែលមានអាជ្ញាខ្ពស់បំផុត និង ប្រកបដោយអំនាចទូលំទូលាយបំផុត»» ។ បើតាម**ស្តាលីន** ដែលបានលើកសំដី**លេនីន**ជាច្រើនដងនោះ វិន័យដែករួមមាន:

- ការមិនអនុញ្ញាតអោយមានការបែកបាក់ផ្ទៃក្នុងបក្ស ។

- ការគោរពតាមបក្សដោយឥតលក្ខខណ្ឌ ។

- ការបោសសំអាតចេញនូវសមាសភាពឱកាសនិយម និង កំនែទំរង់និយម ។ គេមិនអាចយកឈ្នះលើពួកប្រភេទទាំងពីរខាងក្រោយនេះតាមរយៈនៃការតស៊ូផ្នែកមនោគមន៍វិជ្ជាបានទេ ។ គេត្រូវតែកំចាត់ពួកប្រភេទនេះចេញ ។ គេត្រូវធ្វើរហូតដល់«« *កំចាត់ចេញជនកុំមុយនីសដ៏ល្អបំផុតថែមទៀតផង នៅពេលណាដែលអ្នកទាំងនោះអាចមានភាពស្អាក់ស្ទើរ*»» នេះបើតាមសំនេររបស់**លេនីន** ។

២៤. ទាំងនេះគឺជាគំរូនៃបក្សកុំមុយនីសដែល**បក្សកុំមុយនីសបារាំង**បានបង្ហាត់បង្ហាញដល់ពួកសមាជិក នៃ មណ្ឌលលទ្ធិម៉ាក្សនៃនិស្សិតខ្មែរ ។ នៅក្នុងបណ្តាសមាជិកនៃមណ្ឌលនេះ មិនមែនគ្រាន់តែមាន **ប៉ុលពត, អៀងសារី, អៀងធីរិទ្ធ, ហ៊ូយន់, ខៀវសំផន, ម៉ីម៉ាន, ជួនមុំ** ប៉ុននោះទេ តែចំពោះអ្វីដែលជាកម្មវត្ថុនៃអង្គជំនុំជំរះបច្ចុប្បន្ននេះ គឺពិសេសមាន **សុនសេន** ។

២៥. នៅឆ្នាំ ១៩៥៤ **សុនសេន**ជាសមាជិកនៃសាខា**បក្សកុំមុយនីសបារាំង** នៅក្នុងផ្ទះកម្ពុជា ។ គឺបុរសនេះហើយដែលក្រោយមកបានក្លាយជាសមាជិកការិយាល័យអចិន្ត្រៃយ៍នៃមជ្ឈិមបក្សជាឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីការពារប្រទេសនៃ**កម្ពុជាប្រជាធិបតេយ្យ** ជាអគ្គមេបញ្ជាការនៃសេនាធិការដ្ឋានហើយក្នុងតួនាទីនេះជាអគ្គបញ្ជាការទាំងលើកងកំលាំងប្រដាប់អាវុធទាំងលើនគរបាលនយោបាយដែលគេហៅថា សន្តិបាល នោះ ។

២៦. គឺ**សុនសេន**ដដែលនេះដែលនឹងក្លាយជាសមាជិកឧត្តមក្រុមប្រឹក្សាជាតិ (អេសអិនស៊ី-SNC) ពោលគឺជាស្ថាប័នដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងសន្តិភាពដើម្បីតំនាងអោយធម្មានុរូបភាព (L"gitimit") និង អធិបតេយ្យភាពរបស់កម្ពុជា ។ គឺ**សុនសេន** ដែលជាអ្នកបង្ហាត់បង្ហាញជនជាប់ចោទជាអ្នកបណ្តុះបណ្តាលនិង ការពារជនជាប់ចោទមុនឆ្នាំ ១៩៧៥ ក៏ដូចជានៅក្រោយឆ្នាំ ១៩៧៩ ជាថ្នាក់លើតាមលំដាប់ឋានានុក្រមក្នុងបណ្តាឆ្នាំដែលជនជាប់ចោទត្រូវទទួលការវិនិច្ឆ័យទោសនៅក្នុងពេលបច្ចុប្បន្ននេះ ។

២៧. **សុនសេន**មានវត្តមាននៅប្រទេសបារាំងពីឆ្នាំ ១៩៥០ ដល់ ១៩៥៦ ។ គាត់បានចូលរួមក្នុងសកម្មភាពនានា**នៃមណ្ឌលលិទ្ធិម៉ាក្សនៃនិស្សិតខ្មែរ** ។ គាត់ជាសមាជិក**បក្សកុំមុយនីសបារាំង** ។ ដូចជាមិត្តនានារបស់គាត់ដែរ គាត់បានប្រលូកចូលទៅក្នុងបណ្តាកិច្ចពិភាក្សាតទល់គ្នាដែលបានអង្រួនពិភពកុំមុយនីស ។ តើមានហេតុការណ៍អ្វីកើតឡើងនៅក្នុងបណ្តាឆ្នាំដែល**សុនសេន** និង អនាគតអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យបានចូល**គណបក្សកុំមុយ នីសបារាំង**នោះ ?

២៨. ដំបូងត្រូវពិនិត្យមើលថា តើមានអ្វីកើតឡើងនៅក្នុងចក្រភពសូវៀត ។ ដំណើរការកាត់ទោសទីក្រុង **ម៉ូស្គូ** ពីឆ្នាំ ១៩៣៦ ដល់ ១៩៣៩ បានផ្តន្ទាទោសប្រហារជីវិតស្ថាបនិកបដិវត្តន៍ឆ្នាំ ១៩១៧ ដ៏ល្បីល្បាញជាច្រើននាក់ហើយបានបង្ហាញថាគ្មានអ្នកណាម្នាក់អាចគេចផុតពីយុត្តិធម៌របស់បក្សបានទេ ។ ហើយនៅពេលដែល**សុនសេន** និង អ្នកឯទៀតចាប់ផ្តើមសាកល្បងលទ្ធិកុំមុយនីសសូវៀតនោះ នៅឯអឺរ៉ុបខាងកើតមានការរៀបចំការវិនិច្ឆ័យទោសដ៏ខ្មរខ្មារជាបន្តបន្ទាប់ទៅលើអ្នកបដិវត្តន៍បរិសុទ្ធប្រកបដោយអតីតភាពស្មើរតែដូចជាវីរបុរសទៅវិញ ។

២៩. នៅចុងឆ្នាំ ១៩៤៩ មានដំណើរការកាត់ទោសនៅទីក្រុង **ប៊ុយដាប៉េស** និង **សូភីយ៉ា** ដែលនៅពេលនោះអ្នកដឹកនាំកុំមុយនីសរាប់សិបនាក់ត្រូវបានដាក់ទោសធ្វើទារុណកម្ម និង ប្រហារជីវិត ។

៣០. នៅខែវិច្ឆិកា ១៩៥២ មានការកាត់ទោសនៅក្នុងទីក្រុងប្រាកលើរូបលោក Rudolf Slansky ជាអគ្គលេខា**បក្សកុំមុយនីសឆេកូស្លូវ៉ាគី**តាំងពីឆ្នាំ ១៩៤៥ រួមជាមួយអ្នកដឹកនាំគណបក្សជាច្រើនទៀតព្រមទាំងសមាជិកនានានៃរដ្ឋាភិបាលផងហើយដែលលោកArthurLondonបានសរសេរព៌ណនារឿងរ៉ាវទាំងនេះនៅក្នុងសៀវភៅរបស់លោកដែលមានចំនងជើងថា:««**ចំលើយសារភាព**»» (L" Aveu) ។ អ្នកដែលត្រូវយកទៅកាត់ទោសពេលនោះភាគច្រើនជាវីរបុរសក្នុងការតស៊ូប្រឆាំងផាស៊ីសនិយមជាវីរបុរសក្នុង កងឯកភាពអន្តរជាតិ នៅអេស្ប៉ាញ និង នៅក្នុងចលនាតស៊ូនាសង្គ្រាមលោកលើកទីពីរ ។ ការកាត់ទោសនេះ មានលក្ខណៈសំខាន់ជាងការកាត់ទោសណាៗទាំងអស់ម្យ៉ាងគឺមកពីបុគ្គលភាពនៃអ្នកជាប់ចោទ និង ម្យ៉ាងទៀតគឺបណ្តាលមកពីការទូងស្គរទូងប៉ោតរបស់ពួកសូវៀត សំដៅអោយលឺខ្ទរខ្ទាយពីការកាត់ទោសនេះផង ។ ការកាត់ទោសនៅពេលនេះគឺដើម្បីបង្ហាញអោយឃើញថាក្នុងសម័យនៃសង្គ្រាមត្រជាក់ ««***វិន័យដែក***»» គឺជាការចាំបាច់ ហើយគេត្រូវតែ««***បោសសំអាតផ្ទៃក្នុង***»» បក្ស ហើយអ្នកណាក៏ដោយទោះជាមានអតីតកាល និង ស្នាដៃយ៉ាងណាក៏ដោយក៏មិនអាចគេចខ្លួនបានដែរ ។ ការកាត់ទោសនេះជាសារបញ្ជូនទៅគ្រប់អ្នកកុំមុយនីសទូទាំងពិភពលោកដើម្បីកាន់តែកៀកស្មាគ្នា និង បំរើសហភាពសូវៀតដោយឥតតវ៉ា ។ នៅឯប្រទេសបារាំង កាសែត L" Humanit" បានរាយការណ៍ជាប់នូវគ្រប់ដំណាក់កាលនៃការកាត់ទោសនេះ ហើយជានិច្ចកាលតែងអំពាវនាវអោយបង្កើន««***ការប្រុងប្រយ័ត្ន បដិវត្តន៍***»» ។

៣១. នៅឯទីក្រុងប៉ារីសវិញ **បក្សកុំមុយនីសបារាំង** ក៏ចង់រត់អោយទាន់គំរូសូវៀត ដោយបានរៀបចំចាប់ពីខែកញ្ញាដល់ ខែធ្នូ ១៩៥២ នូវការកាត់ទោសរបស់ខ្លួនផងដែរ ។ ការកាត់ទោសនេះ ដូចជាកាត់ទោសនៅអឺរ៉ុបខាងកើតដែរគឺសំដៅលើពួកកុំមុយនីសដែលមានអតីតភាពប្រកបដោយវីរភាពជាតួសំខាន់នៃការការពារសាធារណរដ្ឋអេស្ប៉ាញ និង ចលនាតស៊ូប្រឆាំងនឹងការកាន់កាប់របស់ពួកអាឡឺម៉ង់ដូចជា៖

- លោក Charles Tillon អគ្គមេបញ្ជាការអាស្លាស្ទ័គ្ររំដោះដែលបានកាន់កាប់តួនាទីទទួលខុសត្រូវយ៉ាងខ្ពស់បំផុតនៅក្នុង**បក្សកុំមុយនីសបារាំង** ក្នុងរយៈពេលកាន់កាប់របស់ពួកអាឡឺម៉ង់ ។ ក្រោយពេលរំដោះ លោកត្រូវបានតែងតាំងជាបន្តបន្ទាប់ជារដ្ឋមន្ត្រីអាកាសចរណ៍រួចជារដ្ឋមន្ត្រីយុទ្ធោបករណ៍ និង ជា រដ្ឋមន្ត្រីសំនង់ ។

- លោក Andr" Marti ដែលជាវីរបុរសដ៏ល្បីល្បាញបំផុតនៃចលនាកុំមុយនីសអន្តរជាតិជាអគ្គស្នងការ **កងឯកភាពអន្តរជាតិ** ក្នុងសម័យសង្គ្រាមអេស្ប៉ាញជាមនុស្សទី ៣ នៅក្នុង**គណបក្សកុំមុយនីសបារាំង** ក្រោយពេលរំដោះ ។

៣២. ជាការពិតហើយនៅក្នុងទីក្រុងប៉ារីស គេមិនបានធ្វើទារុណកម្មលោក Tillon និងលោក Marti ទេ។ គេក៏មិនបានប្រហារជីវិតលោកទាំងពីរនេះដែរ ប៉ុន្តែពួកគេត្រូវបានស្ថិតនៅក្នុងដំណើរការបន្ទាបបន្ថោកតែមួយដែលបានធ្វើឡើងនៅឯអឺរ៉ុបខាងកើតដូចជា:

- ភាពអាម៉ាស់ដែលត្រូវសង្កត់បន្ថែមដោយភាពឯកោបណ្តាលមកពីការដែលគណបក្សបានថ្កោលទោសខ្លួនប្រាប់ទៅសមមិត្តឯទៀតរបស់ខ្លួន ។

- ការទាត់ចោលទាំងស្រុងនូវជនជាប់ចោទ ហើយមួយជីវិតដែលបានធ្វើសកម្មភាពបំរើបក្សត្រូវបានគេលើកយកមកជាបញ្ហា ។

- ការមួលបង្កាច់ចោទលើបទចារកម្មអំពើក្បត់សកម្មភាពស៊ីរូងបំផ្លាញបក្ស និង ប្រជារាស្ត្រ ។

- ការខ្ទប់ក្នុងរង្វង់វិចារវិទ្យា (Enfermement Dialectique): ឬមួយអ្នកជាប់ចោទទទួលស្គាល់កំហុសខ្លួនទាត់ចោលការប្តូរផ្តាច់ស្មោះត្រង់រាប់ឆ្នាំរបស់ខ្លួនក្លាយខ្លួនជាអ្នកថ្កោលទោសខ្លួនឯងផ្ទាល់ហើយនៅបំរើបក្ស ឬមួយប្រកែកហើយក្លាយខ្លួនជាសត្រូវវណ្ណៈ ។

គឺដំណើរការបន្ទាបបន្ថោកនេះហើយដែលជាស្នូលនៃវិធីដែលបានប្រើប្រាស់នៅក្នុងមន្ទីរ **ស២១** ។

៣៣. គេអាចមើលឃើញហើយថាក្នុងរយៈពេលដែលពួកគេស្នាក់នៅប្រទេសបារាំងពួកអ្នកដែលនឹងក្លាយខ្លួនជាមេដឹកនាំ**កម្ពុជាប្រជាធិបតេយ្យ** បានទទួលនូវការអប់រំនយោបាយមួយដែលលក្ខណៈសំខាន់គឺមួយភាគធំទទួលឥទ្ធិពលគំរូពួក**បុលឆេវិច** និង ការអនុវត្តជាក់ស្តែងតាមរបប**ស្តាលីន** ។ ហើយដូចជាបានបញ្ជាក់ពីខាងលើមកហើយនិស្សិតម្នាក់ក្នុងចំនោមនិស្សិតខ្មែរទាំងនោះនៅពេលក្រោយមកទៀតជាអ្នកបង្ហាត់បង្ហាញជាអ្នកការពារ និង ជាប្រធានតាមផ្លូវឋានៈនុក្រមរបស់ជនជាប់ ចោទនេះ ។

៣៤. ថ្វីបើគំរូរបស់សូវៀតជាប្រភពមនោគមន៍វិជ្ជាដ៏សំខាន់មិនអាចប្រកែកបានក្តីក៏គេមិនត្រូវភ្លេចផងដែរទេនូវការរួមចំណែករបស់ពួកកុំមុយនីសវៀតណាមនៅក្នុងក្របខណ្ឌ**បក្សកុំមុយនីសឥណ្ឌូចិន** និង ក្រោយមកទៀតក្នុងក្របខណ្ឌ **បក្សកុំមុយនីសវៀតណាម** ។ វណ្ណកម្មផ្នែកទ្រឹស្តីរបស់**ហូជីមិញ** ត្រូវបានបូកបញ្ចូលទៅក្នុងប្រភពនានានៃលទ្ធិម៉ាក្ស-លេនីន ។ យើងត្រូវចាំថា**ហូជីមិញ**បានមានវត្តមាននៅក្នុង ប្រទេសបារាំងនាឆ្នាំ ១៩២០ ក្នុងសន្និសីទទីក្រុងតួ (Congr—s de Tours) ដែលនៅក្នុងពេលនោះ សន្និសីទបានពិចារណា និង ពិភាក្សាយ៉ាងយូរលើលក្ខខណ្ឌទាំង ២១ ដែលលើកឡើងដោយ**លេនីន** ដើម្បីក្លាយជាបក្សកុំមុយនីសមួយទទួលស្គាល់ដោយអង្គការ **កុំមីនទែន** ។ ឥទ្ធិពលផ្នែកមនោគមន៍វិជ្ជារបស់វៀតណាមក៏មិនសូវខុសគ្នាប៉ុន្មាននឹងមនោគមន៍វិជ្ជាសូវៀតដែរទេ ។ ប្រភពវៀតណាមជាការចំលងចេញពីប្រភពសូវៀត ហេតុនេះគ្មានអ្វីថ្មីថ្មោងទេ ប៉ុន្តែជាការសំខាន់ដែលត្រូវតែរំលឹកដោយហេតុថាគឺចេញពីប្រភពវៀតណាមនេះហើយដែល**នួនជា**ទទួលការបណ្តុះបណ្តាលចាប់ពីឆ្នាំ ១៩៥០ មកហើយចាប់ពីឆ្នាំ ១៩៧៧ មកមនុស្សនេះកាន់តួនាទីជាថ្នាក់លើផ្ទាល់របស់ជនជាប់ចោទ ។ ពីឆ្នាំ ១៩៥២ ដល់ឆ្នាំ ១៩៥៥ **នួនជា**ទទួលការបណ្តុះបណ្តាលនយោបាយយ៉ាងល្អិតល្អន់នៅវៀតណាមខាងជើង ។

តាមខ្លួនខ្ញុំផ្ទាល់គេអាចពន្យល់ការប្រើសប្បដិភ័យ (Terreur) ជាវិធីដឹកនាំរដ្ឋតាមបីបែប។

## ប្រភពទីមួយនៃបំរើបំរាស់សប្បដិភ័យជាវិធីដឹកនាំរដ្ឋ: វប្បធ៌មអំពើហឹង្សា

៣៥. ក្នុងឋានៈជាអ្នកទទួលខុសត្រូវលើកម្មវិធី ««វប្បធ៌មសន្តិភាពនៅកម្ពុជា»» របស់អង្គការយូនេស្កូ ខ្ញុំបានធ្វើការសិក្សាអំពីអំពើហឹង្សានៅក្នុងសង្គមកម្ពុជាដែលបានកកើតឡើងនៅក្នុងបណ្តាឆ្នាំសោកនាដកម្មនាទសវត្សចិតសិបកន្លងមក ។ ប៉ុន្តែទោះចង់ឬមិនចង់គេត្រូវទទួលស្គាល់ថាអំពើហឹង្សានេះមិនមែនជាបាតុភាពថ្មីទេ ។

៣៦. គឺជាប្រវត្តិការណ៍ (Faits Historiques) ទៅហើយដែលថាអំពើហឹង្សានយោបាយបានទាមជាប់នឹងសាច់ឈាមនៃសង្គមខ្មែរ ។ ទោះបីជាគេគ្រាន់តែកំរិតយកត្រឹមសម័យដែលចាប់ផ្តើមឯករាជភាពរបស់ ប្រទេសនៅឆ្នាំ ១៩៥៣ មកចុះគេនឹងឃើញនូវបញ្ហានេះយ៉ាងប្រច័ក្ស ។ ដំបូងបង្អស់គឺ**គណបក្សប្រជាធិបតេយ្យ** និងបន្ទាប់មកទៀតគឺ**គណបក្សកុំមុយនីស**សុទ្ធតែជាកម្មវត្ថុនៃការបង្ក្រាបជាប្រព័ន្ធជាបន្តបន្ទាប់ ។ ពួកអ្នកដឹកនាំនយោបាយពួកអ្នកកាសែតប្រឆាំងត្រូវបានគេធ្វើឃាត ។ អ្នកប្រឆាំងនានាត្រូវបានគេយកទៅបាញ់ចោលហើយរូបភាពនៃការប្រហារជីវិតនេះត្រូវបានបញ្ចាំងតាមបច្ចុប្បន្នភាពភាពយន្តរហូតដល់ចង់ឆ្អើម ។

៣៧.  នៅក្នុងរង្វង់ឆ្នាំ ៥០ ជនជាប់ចោទនៅក្មេងណាស់ដើម្បីចងចាំបានពីអំពើហឹង្សាទាំងឡាយដែលបានប្រព្រឹត្តទៅលើបុគ្គលនានាដែលឈានទៅដល់ការកំទេច**គណបក្សប្រជាធិបតេយ្យ** ប៉ុន្តែការធ្វើឃាតលោក **ណុបបុផាន់** នាយកចាងហ្វាងកាសែតឆ្វេងនិយមឈ្មោះ **ប្រជាជន** នាខែតុលាឆ្នាំ ១៩៥៩ ការបំពានលើរូបរាងកាយនិងការបំបាក់មុខជាសាធារណៈទៅលើលោក **ខៀវសំផន** ដែលកាលនោះជាចាងហ្វាងកាសែត L'Observateur (អ្នកសង្កេតការណ៍) នាខែកក្កដា ឆ្នាំ ១៩៦០ ការចាប់ខ្លួនអ្នកធ្វើអត្ថាធិប្បាយទាំងអស់នៃបណ្តាកាសែតឆ្វេងនិយមនៅក្នុងឆ្នាំដដែលនោះ ហើយនៅពេលដែលត្រូវបានលែងខ្លួនមកវិញនៅពេលក្រោយមកទៀតអ្នកទាំងនោះបានអោយដឹងថាពួកគេត្រូវទទួលរងទារុណកម្មការបិទកាសែតប្រឆាំងទាំងអស់ និង ការធ្វើឃាតអគ្គលេខាធិការបក្សកុំមុយនីសនាខែកុម្ភៈ ១៩៦២ អំពើឃោរឃៅរបស់នគរបាលទៅលើពួកនិស្សិតនិងទៅលើយុវជនជាទូទៅនៅក្នុងខែកុម្ភៈ ១៩៦៣ ការប្រហារជីវិតដោយមានការថតភាពយន្តយ៉ាងលំអិតលើរូបលោកព្រាបអ៊ិនហើយបញ្ចាំងជាបច្ចុប្បន្នភាពភាពយន្តអស់រយៈពេលមួយខែនៅឆ្នាំ ១៩៦៤ សុទ្ធសឹងតែជាអំពើហឹង្សាដែលបានផ្តិតជាប់យុវជនខ្មែរនាទសវត្សហុកសិប ។ នៅសម័យនោះជនជាប់ចោទមានអាយុម្ភៃឆ្នាំ ។

៣៨. នៅក្នុងការគ្រប់គ្រងរបស់**សម្តេចសីហនុ** គ្រាន់តែបោះពុម្ពផ្សាយកំនាព្យកាលពីសតវត្សទី ១៧ ស្នើសុំអោយមន្ត្រីរាជការកុំធ្វើបាបប្រជារាស្ត្រក៏ត្រូវជាប់គុកដែរ ។

៣៩.  នៅពេលចាប់ផ្តើមសង្គ្រាមអាមេរិចនៅវៀតណាម  អំពើហឹង្សាកាន់តែមានសភាពខ្លាំងក្លាឡើងថែមទៀត ។ អំពើ ហឹង្សានេះមានមកពីខាងក្រៅផង មានមកពីខាងក្នុងផង ។

៤០.  ភូមិខ្មែរនានាដែលនៅជាប់ព្រំប្រទល់វៀតណាមត្រូវបានទទួលការវាយប្រហារពីសំនាក់កងទ័ពវៀតណាមខាងត្បូងដែលបង្វឹកបង្ហាត់ដឹកនាំដោយពួកនាយទាហានអាមេរិចបង្កជាការបាត់បង់ជីវិតមនុស្សរាប់រយនាក់ ។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ១៩៦៩ មកក្រោមកិច្ចប្រតិបត្តិការឈ្មោះ Menu  យន្តហោះទំលាក់គ្រាប់បែក **បេ៥២** របស់កងទ័ពអាកាសអាមេរិចបានធ្វើអោយមានជនរងគ្រោះស៊ីវិល រាប់ពាន់នាក់ ។

៤១.  ទោះជាក្នុងស្ថានភាពបែបនេះហើយក្តី ក៏អំពើហឹង្សាបង្កឡើងដោយអាជ្ញាធរខ្មែរមិនមានការថមថយចុះឡើយ ។ ការបះបោររបស់កសិករនៅសំឡូតឆ្នាំ  ១៩៦៧-១៩៦៨  ហើយដែលត្រូវបានគណបក្សកុំមុយនីសកម្ពុជាកេងយកចំនេញនយោបាយនាពេលក្រោយមកទៀតនោះ  ត្រូវបានជាមុខសញ្ញានៃការបង្ក្រាបដ៏ឃោរឃៅមួយស្ទើរតែមិនអាចជឿបាន៖  ភូមិនានាត្រូវរងការទំលាក់គ្រាប់បែកកសិករត្រូវសំលាប់រង្គាលពួកអ្នកជាប់ទោសត្រូវរងទារុណកម្មរួមជាមួយនឹងប្រពន្ធរបស់ខ្លួនផងដែរ ។ គេបានឃើញនូវការប្រហារជីវិតដ៏ព្រៃផ្សៃមួយរកអ្វីមកប្រៀបផ្ទឹមមិនបាន ។

៤២. អំពើហឹង្សាកាន់តែមានកំរិតខ្ពស់ឡើងទៀតជាមួយនឹងការដែលប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងសង្គ្រាមដែលបានឆាបឆេះឡើងក្រោយពីរដ្ឋប្រហារស្និទ្ធអាមេរិចមួយនា ខែ មីនា ឆ្នាំ ១៩៧០ ។

៤៣. ការតវ៉ារបស់ពួកអ្នកដែលប្រឆាំងរដ្ឋប្រហារត្រូវបានបង្ក្រាប យ៉ាងសាហាវហើយចំនួនអ្នកស្លាប់ដោយការបង្ក្រាបនេះមានចំនួនរាប់រយនៅក្នុងខេត្តទាំងបួនដែលមានចលនានេះ ។

៤៤. ប្រជារាស្ត្រស៊ីវិលត្រូវបានសំលាប់រង្គាលដោយគ្រាន់តែពួកគេស្ថិតនៅក្នុងពូជសាសន៍ផ្សេង ។ គេបានឃើញនូវការកាប់សំលាប់ផ្តាច់ពូជន៍លើប្រជាជនវៀតណាមហើយដែលទំហំនៃការកាប់សំលាប់ នេះបានធ្វើអោយមានការរញ្ជួយមតិអន្តរជាតិមួយរយៈពេលដែរ ។

៤៥. ការទំលាក់គ្រាប់បែកតែពីសតែពាសរបស់អាមេរិចលើភូមិខ្មែរនានានោះបានត្រូវពង្រីករាយពេញ មួយប្រទេសតែម្តង ។ ខ្ញុំយល់ឃើញថាជាការសំខាន់ដែលត្រូវរំលឹកនៅទីនេះថា ក្រោយពីលោកប្រធា នាធិបតី **ប៊ីលគ្លីនតុន** បានបញ្ជាអោយផ្សព្វផ្សាយរាល់ឯកសារទាក់ទិនទៅនឹងការទំលាក់គ្រាប់បែក អាមេរិចលើប្រទេសកម្ពុជា មកយើងបានដឹងថាគ្រាប់បែកចំនួន ២ ៧៥៦ ៩៤១ តោនត្រូវបានទំលាក់ មកលើប្រទេសកម្ពុជាក្នុងរយៈពេលពីថ្ងៃទី ៤ តុលា ១៩៦៥ ដល់ថ្ងៃទី ១៥ សីហា ១៩៧៣ តាមរយៈ ការចេញហោះហើរនៃយន្តហោះទំលាក់គ្រាប់បែកចំនួន ២៣០ ៥១៦ ជើង ។ ជាការប្រៀបធៀប គ្រាប់ បែកចំនួន ១៦០ ០០០ តោនត្រូវបានទំលាក់ទៅលើប្រទេសជប៉ុនក្នុងចន្លោះឆ្នាំ ១៩៤២ ដល់ ១៩៤៥ និង គ្រាប់បែកចំនួន ១ ៣៥០ ០០០ តោន ត្រូវបានទំលាក់ទៅលើប្រទេសអាឡឺម៉ង់ ក្នុងចន្លោះឆ្នាំ ១៩៤០ ដល់ ១៩៤៥ ។ ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិទាំងមូល មិនដែលមានប្រទេសណារងការទំលាក់គ្រាប់បែកជាងប្រទេសកម្ពុជាទេ ។

៤៦. ទីប្រជុំប្រជននានាដូចជា**មេមត់** និង **ស្នួល**ជាដើមត្រូវកំទេចរាបដល់ដី។សាកលវិទ្យាល័យតាកែវ -កំពតត្រូវបានកំទេចជាផេះ ។ ប្រលាយស្រោចស្រពស្រែរាប់រយគីឡូម៉ែតត្រូវបានបំផ្លាញ ។ ថ្នាំជំរុះស្លឹកឈើរុក្ខជាតិដែលកងទ័ពអាមេរិចបានពង្រាយបានធ្វើអោយព្រៃ និង ចំការកៅស៊ូ ១៥០ ០០០ ហិចតា រងនូវជាតិពុល ។

៤៧. នៅក្នុងសង្គ្រាម ១៩៧០-១៩៧៥ ការប្រយុទ្ធរមែងភ្ជាប់ដោយការអនុវត្តសកម្មភាពឃោរឃៅបំផុតដោយភាគីទាំងពីរៈ ការធ្វើទារុណកម្មជាប្រព័ន្ធ ការកាត់ក្បាលរូងយកថ្លើម ។ អ្វីៗបានប្រព្រឹត្តទៅបាន ដោយសេរីគ្មានការហាមឃាត់អ្វីទាំងអស់ និង ដោយជាន់ឈ្លីទាំងស្រុងនូវភាពថ្លៃថ្នូររបស់មនុស្ស ។ ប្រទេសកម្ពុជាបានត្រូវជ្រមុជចូលទៅក្នុងអំពើហឹង្សាពុះពោរតែម្តង ។ ប្រការនេះបានជះឥទ្ធិពលទៅ លើទំនើរបស់មនុស្សម្នាក់ៗ

តែម្តង។ការដោះស្រាយរាល់ទំនាស់តាមរយៈអំពើហឹង្សាបានក្លាយទៅជាលំនាំប្រព្រឹត្តមួយហើយការសំលាប់គឺជាមធ្យោបាយតែមួយដើម្បីដោះស្រាយទំនាស់។

## ប្រភពទីពីរនៃបំរើបំរាស់សប្បដិភ័យជាវិធីដឹកនាំរដ្ឋ: វប្បធ៍មនយោបាយនៃពួកអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ

៤៨. ដូចជាខ្ញុំបានរំលឹករួចមកហើយ ពួកអ្នកដឹកនាំ **កម្ពុជាប្រជាធិបតេយ្យ** សំខាន់ៗត្រូវបានបណ្តុះ បណ្តាលជាពិសេសនៅប្រទេសបារាំង អោយទទួលនូវបញ្ញត្តិរបស់ពួក**បុលឆេវិច** និង ការអនុវត្តលទ្ធិ កុំមុយនីសតាមបែប**ស្តាលីន** ។ យើងបានឃើញហើយថាតើគោលការណ៍ទាំងឡាយរបស់**លេនីន**ស្តី ពីតួនាទី និងការប្រព្រឹត្តទៅរបស់បក្សមានយ៉ាងណា: វិន័យដែក និង ការកំចាត់រាល់សមាសភាពគួរ អោយសង្ស័យទាំងឡាយ ។ ««*ស្វែងរកសត្រូវនៅក្នុងផ្ទៃបក្ស*»» គឺជាចំនងជើងនៃសេចក្តីសំរេចចិត្តមួយ របស់ Kominform នាខែវិច្ឆិកា ឆ្នាំ ១៩៤៩ ។ នេះជាសេចក្តីណែនាំមួយ ដែល Rakosi អគ្គលេខាធិការ **គណបក្សកុំមុយនីសហុងគ្រី** ហើយដែលជាមេគំនិតនៃការវិនិច្ឆ័យទោសទាំងឡាយនៅអឺរ៉ុបខាងកើតនោះ បានបកស្រាយទៅជា: ««*ចាប់មនុស្សស្លូតត្រង់ដោយភាន់ច្រលំ គ្រាន់បើជាងប្រថុយបណ្តោយ អោយមនុស្សមានទោសនៅមានសេរីភាព*»» ។ នៅក្នុងសម័យនោះ ឃ្លានេះត្រូវបានចុះផ្សាយដោយ កាសែត L‵Humanit‵ ។ ក្នុងសម័យ**កម្ពុជាប្រជាធិបតេយ្យ** ឃ្លានេះត្រូវបានបំបែកចេញជាពាក្យស្លោក ពីរ គឺ: ««*សុខចិត្តចាប់មនុស្សច្រលំដប់ជាជាងលែងមនុស្សច្រលំមួយ*»» និង ««*សំលាប់ច្រលំមនុស្សស្លូត ត្រង់ម្នាក់គ្រាន់បើជាងច្រលំអោយខ្មាំងម្នាក់រស់*»» ។ គេគួរកត់សំគាល់នូវការរអិលផ្នែកនិយណ្ឌសាស្ត្រ (Glissement S‵mantique) ដែលការបំបិទសេរីភាពប្រែទៅជាការកំទេចរូបរាងកាយទៅវិញ ។

៤៩. នេះក៏មិនខុសពីអ្វីដែលលោក Arthur Kístler ដែលជាសមាជិកម្នាក់នៃ**បក្សកុំមុយនីសអាឡឺម៉ង់** ពីឆ្នាំ ១៩៣១ ដល់ ១៩៣៨ និង ជាភ្នាក់ងារម្នាក់នៃអង្គការ Komintern បានលើកឡើងថា:««*ដើម្បីដោះ ស្រាយការខ្វែងមតិគ្នាពួកយើងស្គាល់តែទឡ្ហីករណ៍មួយប៉ុណ្ណោះ : មរណៈ*»» ។

៥០. ថ្នាក់ដឹកនាំ**បក្សកុំមុយនីសកម្ពុជា**បានអនុវត្តគ្មានខុសមួយបន្ទាត់នូវទស្សនាទានសូវៀតស្តីពីបក្សទៅតាមអ្វីដែលភាគច្រើននៃសមាជិកបក្សនេះបានសង្កេតឃើញពីពេលនៅទីក្រុង**ប៉ារីស**នោះមក ។

១. **<u>បក្សកុំមុយនីសកម្ពុជា ត្រូវបានដឹកនាំដោយថ្នាក់មជ្ឈឹមមួយ</u>** «« *ដែលប្រកបដោយអំនាចទូលំ ទូលាយ*»»: នេះជាគណៈអចិន្ត្រៃយ៍មួយដែលមានមនុស្សប្រាំពីរនាក់ និង សមាជិកបំរុងពីរនាក់ ។ គឺជាក្រុមដ៏តូចនេះហើយដែលបានប្រមូលផ្ដុំអំនាចជាសារវន្ត ។ **សុនសេន** ជាសមាជិកនៃក្រុមនេះ ។

គណៈអចិន្ត្រៃយ៍នេះដែលមានសមាជិកនានាបំពេញការងាររបស់ខ្លួននៅក្នុងប្រព័ន្ធអគារស្មុគស្មាញ ដែលមានឈ្មោះជាកូតហៅថា ««**គណៈ៨៧០**»» ទទួលក្នុងការជាក់ស្ដែងនូវរាល់ការងារទទួលខុសត្រូវដែលលក្ខន្តិកៈរបស់**គណបក្សកុំមុយនីសកម្ពុជា**ប្រគល់អោយទៅគណៈកម្មាធិការកណ្ដាល ។ នៅក្នុង រាល់វិស័យ (ការងារចាត់តាំងបក្ស ការងារគ្រប់គ្រង សេដ្ឋកិច្ច កិច្ចការពារ សន្តិសុខ) គណៈអចិន្ត្រៃយ៍បានអនុវត្តនូវអំនាចផ្ដាច់ការទាំងស្រុងលើរាល់អង្គការចាត់តាំងរបស់រដ្ឋក៏ដូចជាលើរបស់ បក្សផងដែរហើយដែលផ្នែកទាំងពីរនេះត្រូវច្របូកច្របល់ចូលគ្នាទាំងអស់ ។

២. **<u>បក្សកុំមុយនីសកម្ពុជាអនុវត្ត««*វិន័យដែក*»»</u>** ដែលមានន័យជាការកំចាត់««*ពួកសត្រូវផ្ទៃក្នុងបក្ស*»» ។ នេះមិនមែនជាការកំចាត់ផ្នែកនយោបាយតែប៉ុននោះទេ តែជាការកំចាត់ផ្នែករូបវន្តផងដែរ ។ ជាការកំចាត់ដែលប្រព្រឹត្តទៅក្រោមពាក្យមួយម៉ាត់ថា: កំទេច ។ កំទេចតាមការពន្យល់របស់ជនជាប់ចោទផ្ទាល់មានន័យថា ចាប់ខ្លួនជាសំងាត់ ប្រើទារុណកម្មដើម្បីសួរចំលើយ រួច ប្រហារជីវិតជាសំងាត់ ។

នៅក្នុងសៀវភៅកំនត់ហេតុការងារមន្ទីរ ស២១ នាឆ្នាំ ១៩៧៦ ស្ដីពីបច្ចេកទេសសារភាព ហើយដែលអ្នកផងហៅថា««**តម្រាស្ដីពីការធ្វើទារុណកម្ម**»» នោះ មានចែងថាគោលដៅនៃបច្ចេកទេសនេះគឺ ««*ទាញយកនូវចំលើយសារភាពអោយបានលំអិតបំផុត*»» ។ លោក Arthur London ដែលបានរស់រានពីការវិនិច្ឆ័យទោសនៅទីក្រុងប្រាក បានរំលឹកនៅក្នុងសៀវភៅរបស់លោកដែលមានចំនងជើងថា ««**ចំលើយ សារភាព**»» ហើយដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៦៨ នោះបានរំលឹកនូវសំដីអ្នកធ្វើទារុណកម្មលើរូបលោកដែលថា:««*អ្វីដែលសំខាន់គឺចំលើយសារភាព*»» ។

នៅក្នុងកិច្ចសន្ទនាមួយក្នុងចំនោមកិច្ចសន្ទនានានាដែលខ្ញុំមានជាមួយជនជាប់ចោទ ទាក់ទិនទៅនឹងការបណ្ដុះបណ្ដាលរូបគាត់ជាអ្នកទទួលខុសត្រូវមណ្ឌលសន្តិសុខនេះ ជនជាប់ចោទបានប្រាប់ខ្ញុំថា ««*ប៉ុលពត និង សុនសេន មានបំនងអោយអនុវត្តតាមបច្ចេកទេសសូវៀត*»» ។

ដូចជានៅទីក្រុង**ម៉ូស្គូ** ទីក្រុង**ប៉ិយការេស** ទីក្រុង**ប៉ិយដាប៉េស** ឬនៅទីក្រុង**ប្រាក**ដែរ គ្មានអ្នកណាម្នាក់អាចគេចរួចឡើយ ។ គ្រាន់តែក្តាប់បានអំនាចភ្លាម **បក្សកុំមុយនីសកម្ពុជា**បានចាប់ផ្តើមកំចាត់សកម្មជនដ៏ល្បីល្បាញមួយចំនួនរបស់ខ្លួនចោលចេញ: **ហ៊ូយន់** (អតីតតំនាងរាស្ត្រ រដ្ឋមន្ត្រី GRUNK និងជារដ្ឋមន្ត្រី**កម្ពុជាប្រជាធិបតេយ្យ**រហូតដល់ពេលត្រូវកំចាត់ចេញ) **ឈូក**(យុទ្ធជនជើងចាស់ខ្មែរ ឥស្សរៈ) **កែវមាស**(សកម្មជនជើងចាស់ **គណបក្សប្រជាជន** ជាស្ថាបនិកម្នាក់នៃ**បក្សកុំមុយនីសកម្ពុជា**) **កែវមនី** (សកម្មជនជើងចាស់ខ្មែរឥស្សរៈ) **ម៉ីផ្ទ** (សកម្មជនជើងចាស់ល្បីល្បាញជាងគេ: លោកបានចូលរួមក្នុងការដណ្តើមអំណាចថ្ងៃទី ៩ ខែសីហា ឆ្នាំ ១៩៤៥) **នងសួន** (រដ្ឋមន្ត្រីកសិកម្ម) ។ អ្នកទាំងអស់នេះត្រូវបានសំលាប់ក្នុងចន្លោះខែមេសា ១៩៧៥ និង ខែធ្នូ ១៩៧៦ ។

**កុយធួន** (រដ្ឋមន្ត្រីក្រសួងកសិកម្ម ជាសហការីរបស់ខៀវសំផននៅក្នុងកាសែត L'Observateur) **ទូចភឿន** (រដ្ឋមន្ត្រីសាធារណការ) **សឿឌឿន** (ដែលទទួលជារដ្ឋមន្ត្រីពាណិជ្ជកម្មបន្តពី**កុយធួន**) **សៀន អាន** (ជាស្ថាបនិកម្នាក់នៃ**មណ្ឌលលទ្ធិម៉ាក្ស**នៅទីក្រុងប៉ារីស) **ភោគឆាយ** (យុវបញ្ញវន្តដែលត្រូវ**សីហនុ**កាត់ទោសជាប់គុកមួយជីវិត) **ទីវអុល** (អតីតសាស្ត្រាចារ្យនិងបញ្ញវន្តឆ្វេងនិយមដែលត្រូវបង្ខំចេញលាក់ខ្លួនពួនអាត្មាចាប់ពីឆ្នាំ ១៩៦៧) និង **ហ៊ូនិម** (អតីតតំនាងរាស្ត្រសម័យសង្គម រដ្ឋមន្ត្រីក្រសួងព័ត៌ មាន) ត្រូវបានសំលាប់នៅក្នុងសប្តាហ៍បន្តបន្ទាប់មកទៀត ។ សូម្បីតែឈ្មោះ **ណាត** ដែលជាប្រធាន **ស២១** ដំបូងគេនោះក៏ត្រូវបានជាប់ឃុំឃាំងនិងបន្ទាប់មកទៀតប្រហារជីវិតនៅក្នុង **ស២១** នេះដែរ។ សមាជិកពីរនាក់នៃគណៈអចិន្ត្រៃយ៍គឺ **វននេត** និង **គង់សុផល** ត្រូវបានប្រហារជីវិតក្នុងឆ្នាំ ១៩៧៨ ។ ទោះជាទទួលមុខការជាប្រធានមណ្ឌលសន្តិសុខណាមួយនៅក្នុងចំនោមមណ្ឌលសន្តិសុខទាំង១៩៦ មិនមែនមានន័យថាអាចរួចខ្លួនបានទេ: ថ្វីបើនៅពេលបច្ចុប្បន្ននេះមានអ្នកខ្លះនៅរស់រានមានជីវិតនៅ ឡើយនិងមិនមានអ្នកណារករឿងក្តី ក៏មានប្រធានមណ្ឌលរាប់សិបនាក់ទៀតត្រូវបានប្រហារជីវិតផងដែរ ។ ចំពោះគ្រប់សមាជិក បក្សទាំងអស់សារមានន័យច្បាស់ណាស់: គ្មានអ្នកណាម្នាក់អាចគេចរួច ខ្លួនបានទេ ។

ប្រការដែល ៨០% នៃជនរងគ្រោះនៅក្នុង **ស២១** កាន់កាប់តួនាទីទទួលខុសត្រូវនៅក្នុង **កម្ពុជា ប្រជាធិបតេយ្យ** បានបង្ហាញពីចំនុចនេះយ៉ាងច្បាស់លាស់ ។ យើងត្រូវបង្ខំចិត្តទទួលស្គាល់ថាបើសិនជាជនមួយចំនួន ក្នុងចំនោមជនរងគ្រោះនេះនៅមានជីវិតនោះពួកគេនឹងក្លាយជាកម្មវត្ថុនៃការវិនិច្ឆ័យទោសរបស់សាលាជំនុំជំរះ ក្តីវិសាមញ្ញនេះផងដែរ ។

៣. <u>**បក្សកុំមុយនីសកម្ពុជាបានធ្វើសកម្មភាពជាសំងាត់តាំងពីឆ្នាំ ១៩៦៣ រហូតមក**</u> ។ គណបក្សនេះបានដាក់អនុវត្តនូវរបៀបលាក់ការណ៍និងវិធីខណ្ឌកាត់ (M‶thode de cloisonnement) ដែលបានក្លាយជាវិធីដឹកនាំមួយរបស់គណបក្ស ហើយចាប់ពីឆ្នាំ ១៩៧៥ មក វិធីនេះបានក្លាយជារបៀបដឹកនាំប្រទេស តែម្តង ។

នៅឆ្នាំ ១៩៧០ នៅពេលដែល**រណសិរ្សរួបរួមជាតិកម្ពុជា** (FUNK) ត្រូវបានបង្កើតឡើង ការលាក់ការណ៍នេះទាក់ទិនទៅនឹងកំលាំងនយោបាយសំខាន់នៅក្នុងរណសិរ្សនេះ ក៏ដូចជាទាក់ទិនទៅនឹងពួកអ្នកដឹកនាំពិតប្រាកដនៅក្នុងកំលាំងនយោបាយនេះ ។ ក្នុងពេញមួយរយៈនៃសង្គ្រាម ក្រៅពីសម្តេច **សីហនុ** ដែលគ្រប់កំលាំងទាំងអស់បានប្រើព្រះនាមព្រះអង្គសំរាប់ការប្រយុទ្ធរបស់ខ្លួននោះ អ្នកដែល ចេញមុខចេញមាត់គឺជាអតីតពួកអ្នកតំនាងរាស្ត្រចំរើននិយមនៃចលនា**សង្គមរាស្ត្រនិយម: ហ៊ូនិម ហ៊ូយន់** និង **ខៀវសំផន** ។ ពួកមនុស្សរាប់ម៉ឺននាក់ដែលបាន««**ចូលព្រៃ**»»ដើម្បីរួមជាមួយ FUNK បាន ត្រឹមតែស្គាល់កម្មវិធីគួរអោយចូលចិត្តរបស់រណសិរ្សនេះតែប៉ុននោះ ។ ពួកគេមិនបានដឹងថា នៅក្នុង FUNK មាន**គណបក្សកុំមុយនីសកម្ពុជា** ។ ពួកគេមិនបានដឹងទាល់តែសោះនូវទិសដៅជាពិសេសរបស់ **បក្សកុំមុយនីសកម្ពុជា** ។

នៅឆ្នាំ ១៩៧៥ នៅពេលដែល FUNK ដណ្តើមបានជ័យជំនះហើយ មានមនុស្សតិចណាស់ដែល បានដឹងថា FUNK ត្រូវបានបក្សកុំមុយនីសកម្ពុជា ពិសេសសមាសភាពរឹងត្អឹងបំផុតនិងដែលដឹកនាំដោយប៉ុលពតនោះត្រួតត្រាបានទាំងស្រុងហើយនោះទេ ។ នៅពេលដែលសមាសភាពនេះត្រួតត្រា លើប្រទេសទាំងមូលនាខែមេសា ឆ្នាំ ១៩៧៥ ពួកគេបានលាក់បំពួនអាត្មាក្រោមនាមដ៏ទូលំទូលាយ មួយហៅថា:««**អង្គការ**»» ។

**សុនសេន**បានថ្លែងយ៉ាងដូច្នេះថា:««*គឺជាការចាំបាច់បំផុតដែលត្រូវរក្សាការសំងាត់*»» ហើយ**នួនជា**ក៏បានសង្កត់បន្ថែមថា:«« *ក្រោយពេលរំដោះ គឺការលាក់ការណ៍ដែលជាមូលដ្ឋាន ។ ការលាក់ការណ៍គឺជាគ្រឹះនៃសកម្មភាពនានារបស់យើង*»» ។ ដើម្បីរក្សាការសំងាត់ និង ខណ្ឌកាត់អង្គការចាត់តាំងរបស់ បក្ស បញ្ហាទាំងឡាយសុទ្ធតែត្រូវបានធ្វើក្នុងនាម **អង្គការ** ទាំងអស់ ។

គឺនៅក្នុងនាម **អង្គការ** ដែលរាល់សេចក្តីសំរេចទាំងអស់ត្រូវបានធ្វើឡើង និង អនុវត្តតាមនៅគ្រប់ជាន់ថ្នាក់ទូទាំងប្រទេស និង នៅក្នុងសកម្មភាពគ្រប់វិស័យ ។ អនាមិកភាពនៃអំនាចពិតប្រាកដបានផ្តល់ ដល់ **អង្គការ** នូវកំលាំងមួយជាពិសេស ព្រោះវាបានបង្កឡើងនូវអារម្មណ៍ពលានុភាព (Puissance) ទន្ទឹម គ្នានោះ បង្កឡើង និង រក្សាជាប់នូវអារម្មណ៍មិនច្បាស់លាស់ និង ការខ្លបខ្លាចក្នុងចំនោមប្រជារាស្ត្រ ។ អារម្មណ៍ និង ការខ្លបខ្លាច

នេះបានរីករាលដាលយ៉ាងរហ័ស ព្រោះគឺក្នុងនាម **អង្គការ** នេះហើយដែលគេ បានធ្វើការជំលៀសប្រជាជនទាំងបង្ខំចេញពីទីក្រុងនានា ការប្តូរទីតាំង ការចាត់តាំងឡើងទាំងបង្ខំនូវសហករណ៍ ប្រជាជននានា ការបំបាត់រូបិយវត្ថុ និង ការធ្វើសម្ងហភាវកម្មក្នុងប្រទេសទាំងមូល ។ រាល់ទិដ្ឋភាពនៃជីវភាពរស់នៅប្រចាំថ្ងៃត្រូវ បានដាក់ក្រោមការត្រួតត្រារបស់ **អង្គការ** ទាំងអស់។

ការភ័យខ្លាចកាន់តែកើនឡើងថែមទៀតនៅពេលដែលគេប្រើនាម **អង្គការ** ដើម្បីកោះហៅមនុស្ស ទាំងពួងហើយអ្នកនោះបាត់ខ្លួនជារៀងរហូត ។ ការភ័យខ្លាចនេះបានប្រែក្លាយទៅជាសប្បដិភ័យនៅពេលដែលការប្រហារជីវិតស្រស់ៗបានត្រូវបន្ថែមពីលើការបាត់ខ្លួននេះថែមទៀត។

រាល់អំនាចទាំងអស់ចេញមកពី **អង្គការ** ហើយ **អង្គការ** នេះទាមទារដាច់ណាត់នូវភក្តីភាពដាច់ខាត និងគ្មានលក្ខខណ្ឌ ។ រាល់កង្វះខាតត្រូវតែសារភាព ឬ រាយការណ៍បើកកកាយ ។ ប្រការនេះបានក្លាយទៅជាការអនុវត្តជាទូទៅនូវរបបរាយការណ៍ដ៏គួរអោយស្អប់ខ្ពើម ។ ម្នាក់ៗលួចឃ្លាំមើលគ្នាទៅវិញទៅមកក្នុងបរិយាកាសសប្បដិភ័យមួយដ៏តានតឹងដែលម្នាក់ជាចំនាប់ខ្មាំងរបស់ម្នាក់ ហើយម្នាក់ៗភ័យខ្លាចខ្លួន បាត់បង់ជីវិត ។

គឺ **អង្គការ** ដែលជាអ្នកកំនត់មាគ៌ានយោបាយ ធ្វើការណែនាំ និង សារាចរនានាដល់កម្មាភិបាលបក្ស យោធា និងសន្តិបាល ។

ការគោរពដាច់ខាតចំពោះ**អង្គការ** គឺដូចគ្នាទៅនឹងការតំរូវនៅក្នុងគណបក្សកុំមុយនីសនៅក្នុងបណ្តា ប្រទេសក្នុងចក្រភពសូវៀតយ៉ាងនោះដែរ ។ ការប្រៀបធៀបពាក្យស្លោកមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យទៅនឹងរូបមន្តដែលត្រូវបានប្រើនៅក្នុងពេលវិនិច្ឆ័យទោសនានារបស់**ស្តាលីន**ដែលខ្ញុំបាន លើកឡើងមុននេះមានភាពប្រហាក់ប្រហែលគ្នាជាពន់ពេក ។

លោក Arthur London បានរំលឹកថា ពួកធ្វើទារុណកម្មលើរូបលោកតែងនិយាយហើយនិយាយទៀតមកលើរូបលោកថា:«« *អែងត្រូវទុកចិត្តបក្សហើយទុកអោយបក្សជាមគ្គុទ្ទេសក៍របស់អែង* »» ។ ពួកធ្វើទារុណកម្មនៅ ស២១ បានបន្ទរពាក្យនេះដោយពួកគេបានសរសេរនៅលើសៀវភៅការងាររបស់ពួកគេដែលខ្ញុំបានលើកពីមុននេះ ថា:«« *អ្វីដែលសំខាន់បំផុតគឺជឿជាក់ដាច់ខាតលើបក្ស* »» ឬថា:«« *ជឿ ជាក់លើបក្ស គោរពតាមការណែនាំរបស់បក្សយ៉ាងដាច់ខាតនិងគ្មានលក្ខខណ្ឌ* »» ។

## ប្រភពទីបីនៃបំរើបំរាស់សប្បដិភ័យជាវិធីដឹកនាំរដ្ឋ: លក្ខណៈជាពិសេសនៃលទ្ធិកុំមុយនីសប៉ុលពតនិយម

**៥១.** លទ្ធិកុំមុយនីសរបស់**កម្ពុជាប្រជាធិបតេយ្យ** ដែលខ្ញុំអោយឈ្មោះថា **លទ្ធិប៉ុលពត** នេះ បានបង្ហាញនូវលក្ខណៈពិសេសមួយចំនួនដែលនៅពេលយើងយកមកពិនិត្យជាប់ៗគ្នាមក បានផ្តល់នូវការបក ស្រាយតែឯកឯងគត់លើទ្រឹស្តីម៉ាក្ស-លេនីន ក្នុងចំនោមការអនុវត្តទាំងឡាយដែលយើងបានស្គាល់មក ទល់នឹងពេលនេះ ។ បំនកស្រាយនេះបានសង្កត់បន្ថែមលើលទ្ធិសប្បដិភ័យរដ្ឋ (Terrorisme d"Etat) ដែលមាននៅក្នុងគ្រប់របបផ្តាច់ការទាំងអស់ ។

**៥២.** **លទ្ធិប៉ុលពត**មិនមានលក្ខណៈអន្តរជាតិនិយមនោះទេ វាមានលក្ខណៈជាតិនិយម ។ ពួកអ្នកដឹកនាំ**កម្ពុជាប្រជាធិបតេយ្យ**បានបញ្ចេញនូវទំរង់វាតទីមួយបែបនៃជាតិនិយមដែលកត់សំគាល់ដោយការទាមទារទឹកដីហួសប្រាកដនិយម ។ សុន្ទរកថានានារបស់ពួកគេនិយាយឡើងពី«« *ទឹកដីដែលត្រូវបាត់បង់*»» និងនិយាយពីការចាំបាច់ដណ្តើមយកមកវិញនូវ«« *គ្រប់កន្លែងណាដែលមានដើមត្នោតដុះ*»» ឬជួនកាលរហូតដល់«« *កន្លែងណាដែលមានសីលាចារឹកខ្មែរ*»» ។ នេះគឺជាដើមហេតុនៃការវាយប្រហារជាបន្តបន្ទាប់ ទៅលើវៀតណាម និង គំនិតងប់ចាត់ទុកវៀតណាមជាសត្រូវ ។ គឺគំនិតងប់នេះហើយ ដែលក្រោយពីការផ្តាច់ចំនងទាក់ទងការទូតនាចុងឆ្នាំ ១៩៧៧ និង ការដាក់ប្រទេសទាំងពីរទៅក្នុងស្ថានភាពមាន សង្គ្រាមមកបាននាំទៅដល់ការកំចាត់ចោលនូវមនុស្សរាប់ម៉ឺននាក់ក្រោមលេសដែលថាអ្នកទាំងនោះ ««*ក្បាលយួនខ្លួនខ្មែរ*»» នោះ ។

**៥២.** លទ្ធិប៉ុលពតមិនមែនជាលទ្ធិប្រជាធិបតេយ្យនោះទេ តែគឺជាទំរង់នៃ លទ្ធិ **អប្បជនាធិបតេយ្យ** (Oligarchie) មួយដ៏ពេញលេញ ។ ក្រុមដឹកនាំ**កម្ពុជាប្រជាធិបតេយ្យ**មិនដែលទទួលបានការគាំទ្រពិត ប្រាកដរបស់ប្រជាជនទេ ។ ការប្រឆាំងតទល់នឹងរបបសាធារណរដ្ឋរបស់**លន់នល់**ត្រូវបានធ្វើតាមព្រះ នាម **នរោត្តម សីហនុ** ដែលជានិមិត្តរូបពីទីឆ្ងាយហើយដែល**ប៉ុលពត** និង ពួកជំនិតរបស់គេជ្រកធ្វើ សកម្មភាពក្រោមនោះ ។ គំរោងនយោបាយរបស់FUNK គ្មានទំនាក់ទំនងអ្វីបន្តិចបន្តួចសោះនឹងនយោ បាយដែល**កម្ពុជាប្រជាធិបតេយ្យ**នឹងប្រកាន់យក ។ សូម្បីតែនៅក្នុងផ្ទៃ**គណបក្សកុំមុយនីសកម្ពុជា** ក៏ មាគ៌ានយោបាយរបស់**ប៉ុលពត** និង បក្ខពួកមិនដែលបានទទួលការគាំទ្រជាចំហដោយភាគច្រើនសោះ ឡើយ ។ មុនឆ្នាំ ១៩៧៥ ក៏ដូចជាក្រោយឆ្នាំ ១៩៧៩ ផងដែរ ពួកកុំមុយនីសខ្មែរដោយភាគច្រើន មិនមានលក្ខណៈតាមបែប**ប៉ុលពតនិយម**សោះឡើយ ។ ប្រការនេះ ហើយដែលបានធ្វើអោយក្រុមពួកដឹកនាំប្រកាន់យកនូវអាកប្បកិរិយាជាបន្ទាយត្រូវ គេហ៊ុមព័ទ្ធហើយដែលខំបង្ហាញភាពស្របច្បាប់របស់ខ្លួន តាមរយៈការអនុវត្តបទបញ្ជាតាមប្រមាញ់««*ពួកខ្មាំងផ្ទៃក្នុង*»» និង ការអនុវត្តការសំលាប់ជាវិធីដឹកនាំរដ្ឋ។

ឯកសារថ្ងៃទី ៣០ មីនា ឆ្នាំ ១៩៧៦ ក្រោមចំនងជើង ថា:««*សេចក្តីសំរេចចិត្តរបស់គណៈមជ្ឈឹមបក្សស្តីពីបញ្ហានានា*»» បានលើកឡើងជាទីមួយនូវបញ្ហា ««*ការកំទេចនៅ ក្នុងជួរ និងក្រៅជួរបក្ស*»» ។

**៥៤. លទ្ធិប៉ុលពត**មានលក្ខណ:ស្វ័យធនភាព (Autarcie) ។ ឆន្ទ:ដែលត្រូវបានលើកជាបាវចនាថា:««*ពឹងផ្អែកលើកំលាំងខ្លួនឯងទាំងស្រុង*»» បាននាំទៅដល់ភាពឯកោហើយដែលបានពង្រឹងអារម្មណ៍បន្ទាយ ត្រូវគេហ៊ុមព័ទ្ធ និង ការសង្ស័យលើគេឯងគ្រប់គ្នា ។

**៥៥. លទ្ធិប៉ុលពត**មានចរិតប្រកាន់ពូជសាសន៍ ។ ««*ត្រូវការពារសុទ្ធភាពនៃពូជន៍សាសន៍ខ្មែរ*»»គឺជាពាក្យស្លោកដែលថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យតែងតែនិយាយហើយនិយាយទៀត។ ឆន្ទ:នេះបានបង្ហាញចេញជាការសំលាប់នូវក្រុមមនុស្សដែលគេអោយនិយមន័យយ៉ាងចំលែក និង យ៉ាងសើៗថាជាពួកខ្មែរកាត់ចិន ខ្មែរកាត់ថៃ ខ្មែរកាត់យួន ចាម ។

**៥៦. លទ្ធិប៉ុលពត** បានដាក់អោយដំណើរការនូវសមូហភាវកម្មមួយដែលមានលក្ខណ:ដាច់ខាត ទាំងស្រុង ។ បន្ទាប់ពីជំលៀសប្រជាជនទាំងបង្ខំចេញពីទីក្រុងនានា ការបង្ខំប្រជាជនទាំងមូលអោយ ផ្លាស់ប្តូរទីលំនៅជាបន្តបន្ទាប់ ការដាក់ជាសមូហភាពនូវដីកសិកម្ម ការបំបាត់រូបិយវត្ថុ និង បំលាស់ប្តូរ នានា គ្មានទ្រព្យសម្បត្តិ ផ្ទះសំបែង ដីធ្លីណាមួយដែលជាកម្មសិទ្ធិបុគ្គលទៀតឡើយ ។ ការដកកម្មសិទ្ធិ គឺទាំងស្រុង ។ ការដកកម្មសិទ្ធិទាំងស្រុងឈានរហូតដល់ខាឃាំងមិនអោយបុគ្គលទាំងអស់មានសិទ្ធិ ទៅលើអត្តសញ្ញាណរបស់ខ្លួន ពេលវេលារបស់ខ្លួន ជំរើសដោយសេរីនូវទំនាក់ទំនងរបស់ខ្លួន រហូត ដល់ទៅដល់ការផ្តល់អោយ កម្មាភិបាល នៃគណបក្សកុំមុយនីសនូវអំនាចជ្រើសរើសគូស្រករអោយ បុរសនិងនារីព្រមទាំងពេលវេលាណាដែលគូ ស្រករត្រូវនៅជាមួយគ្នាថែមទៀតផង ។ នៅក្នុងសហករណ៍ដែលមានការ ប្រមូលផ្តុំជនជាតិខ្មែរ ពួកគេរមែងគ្មានសិទ្ធិទាំងទៅលើឧបភោគភណ្ឌដែលគេប្រើសំរាប់ទទួលទានថែមទៀតផង ។

**៥៧.** នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ មិនដែលមានសោះឡើយនូវការជំរុញសមូហភាវកម្មយ៉ាងឆ្ងាយដូចនៅក្នុង**កម្ពុជាប្រជាធិបតេយ្យ**នេះ ។ មិនដែលមានសោះឡើយនៅក្នុងប្រវត្តិមនុស្សដែលការលុបបំបាត់ នូវភាពថ្លៃថ្នូរដែលមាននៅក្នុងមនុស្សម្នាក់ៗត្រូវបានជំរុញយ៉ាងឆ្ងាយបែបនេះ ។ មិនដែលមានរបបនយោបាយមួយណាដែលបានបំបាត់កម្មសិទ្ធិអាត្មន័ខ្លួន មិនមែនតែចំពោះមនុស្សមួយប្រភេទ ណាដែលគេ កំនត់នោះទេ តែគឺចំពោះប្រជារាស្ត្រទាំងមូលរាប់ទាំងអ្នកដែលបានបំរើរបបនេះផងដែរ ។

**៥៨.** **លទ្ធិប៉ុលពត**បានបង្ហាញនូវឆន្ទៈឈានទៅកាន់សង្គមថ្មី«*ក្នុងជំហានលោតផ្លោះតែមួយផ្លោត*» ដោយមិនបាច់ឆ្លងកាត់តំនាក់អន្តរកាលអ្វីទាំងអស់ ។ នេះជាការធ្វើអោយលើស**លេនីន** និង **ស្តាលីន** ទៅអោយហួសពួកចិននិងវៀតណាមក្នុងការកសាងសង្គមមួយតាមបំនងប្រាថ្នារបស់ពួកគេ ។ បំលែងប្តូរនានាយ៉ាងដាច់ខាតនិងទាំងស្រុងត្រូវបានគេដាក់អោយដំណើរការក្នុងកំរិតមួយដែលគ្មានអ្វីប្រៀប
បានដោយគ្មានគិតអ្វីបន្តិចណាសោះទៅលើតំលៃមនុស្សដែលត្រូវបង់ ។

**៥៩.** នៅទីបញ្ចប់ ដូចជាមានគំរូដ៏កម្រនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិផងដែរ**លទ្ធិប៉ុលពត**បានបង្ហាញនូវការប្រមាថទាំងស្រុងលើបុគ្គលមនុស្ស ដូចពាក្យស្លោកពួកគេដែលថា«*បេះដូងយើងគ្មានមនោសញ្ចេតនា គ្មានការយោគយល់*» ឬ «*តវ៉ាខ្លាំង ប្រឆាំងខ្លោច*» ជាដើម ។

## លោកប្រធានលោកស្រី អស់លោកជាសមាជិកនៃអង្គជំនុំជំរះ

**៦០.** ជនជាប់ចោទបានអះអាងថាខ្លួនជាអ្នកបំរើផង ជាចំនាប់ខ្មាំងផងនៃរបបបែបនេះ ។ ការវិភាគដែលខ្ញុំទើបនឹងបានបង្ហាញជូនលោកស្រី និង អស់លោកកន្លងមកនេះ អាចអោយខ្ញុំនិយាយថាស្ថានភាពដែលជនជាប់ចោទបានព៌ណនានេះជាការពិត ។

**៦១.** បញ្ញវ័ន្តប្រឆាំងផាស៊ីសដ៏ល្បីល្បាញម្នាក់ និង ជាអ្នកនិពន្ធបារាំងដ៏ល្បីល្បាញនាសតវត្សទីម្ភៃ ព្រមទាំងជាអ្នកដែលបានធ្វើការតស៊ូប្រឆាំងរបបប្រង់កូ (frankisme) និងរបបណាស៊ីផងដែរនោះ បានថ្លែងថា:«*យើងបានប្រកែកមិនធ្វើតាមអ្វីដែលធាតុតិរិច្ឆានចង់អោយយើងធ្វើ ហើយយើងចង់រកអោយឃើញមនុស្សនៅគ្រប់ទីកន្លែងណាដែលយើងរកឃើញអ្វីដែលសង្កត់សង្កិនរូបគេ*» ។

**៦២.** គេបានឃើញថា នៅក្នុងថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៅកម្ពុជា មានពួកស្ត្រី និង បុរសដែលបានអនុញ្ញាតអោយធាតុតិរិច្ឆានដែលមាននៅក្នុងខ្លួនយើងគ្រប់គ្នា បំពេញអកុសលកម្មដោយសេរីគ្មាន ការខាឃាំងអ្វីទាំងអស់ ។

**៦៣.** គឺពួកក្រុមនេះហើយដែលបានបើកអោយមានអំពើរឃោរឃៅហើយពួកគេត្រូវទទួលខុសត្រូវយ៉ាង ធ្ងន់ធ្ងរ និងដំបូងគេបំផុត ។

**៦៤.** ពួកអ្នកដែលដើរតាមក្រុមពួកនេះ ទោះជាដោយតាមការស្តាប់បង្គាប់ក្តី ទោះជាដោយភាពខ្ជះខ្ជែង ក្តី ក៏មិនអាចចាត់ថាមិនមានកំហុសនោះទេ ។

**៦៥.** ប៉ុន្តែបើនិយាយអោយដល់ជំរៅទៅ តើអ្នកណាម្នាក់ដែលស្ថិតនៅចំពោះមុខទ្វេគ្រោះ (Dilemme) ដែលដាក់ថាតើត្រូវសំលាប់ ឬ ត្រូវអោយគេសំលាប់ ព្រមធ្វើពលិកម្មខ្លួនឯងនោះ?

**៦៦.** លោក **រ៉ា អ៊ូល ចេណា** ( Raoul Jennar ) ជាជនជាតិ បែលស៊ិច និងជាអ្នកជំនាញផ្នែកច្បាប់រដ្ឋធម្មនុញ្ញ ។ បច្ចុប្បន្ននេះលោកបានបំពេញការងារជាទីប្រឹក្សានៃរាជរដ្ឋាភិបាលកម្ពុជា ។ ការពីខែកញ្ញានេះលោកបានចូលធ្វើចំលើយកសិណាមួយនៅអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាជុំវិញជនជាប់ចោទ នាម **កាំង ហ្កេចអ៊ាវ** ហៅ **ឌុច** ។ ដោយឃើញថា ចំលើយកសិណា នេះមានសារសំខាន់សំរាប់ការស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជាទស្សនាវដ្តី **កម្ពុជា** យើងសូមបកប្រែចុះផ្សាយទាំងស្រុងដូចខាងក្រោមនេះ ៖

**អង្គជំនុំជំរះវិសាមញ្ញ ភ្នំពេញ ថ្ងៃទី ១៤ កញ្ញា ឆ្នាំ ២០០៩**

ប្រែសំរួលដោយខៀវកាញារីទ្ធ